**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

❀❀❀❀❀❀❀

**ក្រសួងអប់រំ យុវជន និង កីឡា**

លេខៈ១៧៧/៨ អយក.ប្រក

# ប្រកាស

## ស្ដីពីការបើកសាលារៀនចំណេះទូទៅឯកជន " **វិទ្យាល័យ ពន្លកខ្មែរ** "

## ស្ថិតនៅក្នុង ឃុំ ប៉ោយប៉ែត ស្រុក អូរជ្រៅ ខេត្ត បន្ទាយមានជ័យ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្ដីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យ លេខ ១៨ អនក្រ ចុះថ្ងៃទី ១៥ មិថុនា ១៩៩២ ស្ដីពីការបើកសាលារៀនចំណេះទូទៅឯកជន
- យោងលិខិតស្នើសុំរបស់ លោក កែវ វីរ៉ា ចុះថ្ងៃទី ១៦ មិថុនា ២០០៦ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និង កីឡា និងអភិបាល ខេត្ត បន្ទាយមានជ័យ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

## សំរេច

**ប្រការ១** : អនុញ្ញាតឱ្យបើកសាលាចំណេះទូទៅឯកជន " **វិទ្យាល័យ ពន្លកខ្មែរ** " ស្ថិតនៅក្នុង ឃុំ ប៉ោយប៉ែត ស្រុក អូរជ្រៅ ខេត្ត បន្ទាយមានជ័យ ចាប់ពីឆ្នាំសិក្សា ២០០៦-២០០៧ តទៅ។

**ប្រការ២** : សាលារៀនឯកជន **វិទ្យាល័យ ពន្លកខ្មែរ** ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត បន្ទាយមានជ័យ និងត្រូវ អនុវត្តកម្មវិធីសិក្សាតាមការអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និង កីឡា។

**ប្រការ៣** : **លោក កែវ វីរ៉ា** ជានាយកសាលាត្រូវដឹកនាំ ចាត់តាំង គ្រប់គ្រងសាលារៀនទាំងផ្នែករដ្ឋបាល និងផ្នែកបច្ចេកទេស ព្រមទាំង ទទួលខុសត្រូវក្នុងការងារ :

- ជ្រើសរើសគ្រូបង្រៀនដែលមានសមត្ថភាពគរុកោសល្យសមស្រប។
- ជ្រើសរើសសិស្សឱ្យចូលរៀន។
- ធានាដំណើរការបង្រៀន និងរៀនឱ្យបានល្អ។
- គោរព និងអនុវត្តសារាចរ សេចក្ដីណែនាំរបស់ក្រសួងអប់រំ យុវជន និង កីឡា។
- ធានាឱ្យមានសុវត្ថិភាព និងសណ្ដាប់ធ្នាប់សង្គម។
- រាយការណ៍រាល់សកម្មភាពសិក្សាជូនមន្ទីរអប់រំ យុវជន និង កីឡា ខេត្ត បន្ទាយមានជ័យ តាមកាលកំណត់ ។

**ប្រការ៤** : ក្រសួងអប់រំ យុវជន និង កីឡា មានសិទ្ធិធ្វើអធិការកិច្ច ត្រួតពិនិត្យ ហើយមានសិទ្ធិបិទ ប្រសិនបើសាលារៀននេះអនុវត្តខុសពីគោលការណ៍អប់រំរបស់រដ្ឋ ។

**ប្រការ៥** : អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត បន្ទាយមានជ័យ និងនាយកសាលារៀនសាមីមាន ភារកិច្ចរៀង១ខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ, ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០០៦

បណ្ឌិត គល់ ផេង

**<u>កន្លែងទទួល:</u>**

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពតិមាន "
- -សាលាខេត្ត បន្ទាយមានជ័យ "ដើម្បីជាពតិមាន"
- -ដូចប្រការ៥
- -កាលប្បវត្តិ-ឯកសារ នា.មចទ